នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារនៃការដាក់ឯកសារ

សំណុំរឿងលេខ	:	០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ	:	អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់	:	ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣
ភាគីអ្នកដាក់	:	សហព្រះរាជអាជ្ញា
ភាសាដើម	:	**អង់គ្លេស**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Aug-2013, 16:00
CMS/CFO: Sann Rada

ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ ជាមួយខ្លះសម្ពន្ធសម្ងាត់បំផុត**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ការបដ្ឋាក្យរបស់សហព្រះរាជអាជ្ញាអន្តរជាតិ
អំពីកំណត់ហេតុស្តាប់ចម្លើយសាក្សីពីសំណុំរឿង ០០៣ និង ០០៤

អ្នកដាក់ឯកសារ:
សហព្រះរាជអាជ្ញា
លោក Andrew CAYLEY

ចម្លងជូន:
លោកស្រី ជា លាង

អ្នកទទួលឯកសារ:
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ឃួ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

ចម្លងជូន:
ជនជាប់ចោទ
ឡួន ជា
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Jacques VERGÈS
លោក Arthur VERCKEN
លោកស្រី Anta GUISSE

I. **ការបង្ហាញ**

១. តាមរយៈការដាក់ឯកសារនេះ សហព្រះរាជអាជ្ញាអន្តរជាតិ សូមបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង នូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលទើបបានផ្តល់ឱ្យដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនាពេលថ្មីៗនេះទាក់ទងនឹងសំណុំរឿង ០០៣ និង ០០៤ នៅចំពោះមុខ អ.វ.ត.ក ហើយដែលស្ថិតនៅក្រោមកាតព្វកិច្ចនៃការបង្ហាញដ៏សំខាន់របស់សហព្រះរាជអាជ្ញា។

២. អង្គជំនុំជម្រះនេះធ្លាប់បានសម្រេចពីមុនថា "វិធាន៥៣(៤) នៃវិធានផ្ទៃក្នុង ដាក់កាតព្វកិច្ចឱ្យសហព្រះរាជអាជ្ញាបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូងជាបន្តបន្ទាប់ នូវសម្ភារៈណាមួយដែលស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួនដែលអាចនឹងបង្ហាញពីនិរទោស ឬការបន្ថយពិរុទ្ធភាពរបស់ជនជាប់ចោទ ឬធ្វើឱ្យប៉ះពាល់ចំពោះភាពជឿទុកចិត្តបាននៃភស្តុតាង"[1]។ សហព្រះរាជអាជ្ញាអន្តរជាតិ ធ្លាប់បានសន្និដ្ឋានថា ការបង្ហាញដូច្នេះក៏ជាលក្ខខណ្ឌតម្រូវនៅក្រោមវិធាន២១(១)[2] ផងដែរ។

៣. នៅក្នុងការដាក់ជូនពីលើកមុនមួយដោយសហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការស្វែងរកការណែនាំពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការបង្ហាញកំណត់ហេតុបន្ថែមដែលបានប្រមូលក្នុងអំឡុងពេលនៃការស៊ើបសួររបស់ ក.ស.ច.ស លើករណីផ្សេងៗរបស់សាក្សីទាំងឡាយដែលធ្លាប់បានផ្តល់សក្ខីកម្ម ឬដែលត្រូវបានកំណត់កាលវិភាគឱ្យមកផ្តល់សក្ខីកម្ម នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងនេះបានបង្គាប់ឱ្យមានការដាក់បង្ហាញបែបដូច្នេះ និងបានណែនាំថា "ប្រសិនបើសហព្រះរាជអាជ្ញាបានដឹងអំពីចម្លើយណាមួយបន្ថែមទៀត ដែលសហចៅក្រមស៊ើបអង្កេតបានទទួលពីសាក្សីក្នុងសំណុំរឿង ០០២ និងសំណុំរឿងផ្សេងទៀតនោះ សហព្រះរាជអាជ្ញាគប្បីដាក់ចម្លើយទាំងនេះមកអង្គជំនុំជម្រះសាលាដំបូង ក្នុងប្រភេទជាឯកសារមានលក្ខណៈដូចគ្នា "[3]។

៤. ដោយធ្វើឱ្យត្រូវទៅតាមកាតព្វកិច្ចនៅក្នុងការដាក់បង្ហាញទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការដាក់បង្ហាញមួយនេះភ្លាម។ ការដាក់បង្ហាញនេះមានផ្ទុកទៅដោយឯកសារនានាដែលបានបង្ហាញនៅលើមូលដ្ឋានបី៖ (ទី១) កំណត់ហេតុនៃការស្តាប់ចម្លើយដែលបានធ្វើឡើងដោយសាក្សីទាំងឡាយដែលធ្លាប់បានផ្តល់ សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១, (ទី២) កំណត់ហេតុនៃការស្តាប់ចម្លើយដែលអាចមានផ្ទុក ទៅដោយភស្តុតាងដោះបន្ទុកទាក់ទងទៅនឹង ខ្លួន ជា និង/ឬ ខ្មៀវ

---

[1] **E127/4,** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២" ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២, ចំណុះ១។

[2] **E127,** ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដល់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង ០០៣ និង០០៤ ដោយមានឧបសម្ព័ន្ធ ក សម្ងាត់បំផុត, ៦ តុលា ២០១១, កថាខណ្ឌទី៦។

[3] **E127/4,** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២", ២៤ មករា ២០១២, ត្រង់ចំណុះទី១។

សំផន, និង (ទី៣) កំណត់ហេតុនៃការស្តាប់ចម្លើយដែលមានផ្ទុកទៅដោយព័ត៌មាន ពាក់ព័ន្ធទៅនឹងសាក្សីទាំងឡាយ ដែលធ្លាប់បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១។ ក្នុងករណីដែលមានការដាក់បង្ហាញនេះក៏ផ្តល់ផងដែរនូវការថតជាសម្លេងដែលទាក់ទងទៅនឹងកំណត់ហេតុទាំងនោះ។

៥. ឧបសម្ព័ន្ធអម បង្ហាញពីអត្តសញ្ញាណនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីស្រង់ដោយ **កសចស ចំនួន១៦** និងខ្សែអាត់ថតសម្លេងចំនួន៩ ដែលមានកានៅក្នុងការបង្ហាញនេះ។ សម្រាប់ឯកសារនីមួយៗ ឧបសម្ព័ន្ធនេះបង្ហាញពីមូលដ្ឋានទូទៅដែលនៅក្នុងនោះឯកសារកំពុងតែត្រូវបានបង្ហាញជូន។ ក្នុងចំណោមឯកសារទាំងអស់នេះ រួមមានកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលត្រូវបានប្រមូលចងក្រងដោយសហចៅក្រមស៊ើបអង្កេត ចាប់តាំងពីពេលបង្ហាញជូនលើកមុនរបស់សហព្រះរាជអាជ្ញានូវឯកសារស្រដៀងគ្នានេះ កាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២មក[4]។

៦. កន្លងមក អង្គជំនុះជម្រះសាលាដំបូងធ្លាប់បានចេញដីកាបង្គាប់ថា ការបង្ហាញជូននូវឯកសារដែលបានមកពីសំណុំរឿងលេខ០០៣ និង០០៤ ចូលក្នុងសំណុំរឿងលេខ០០២ ជាដំបូងបង្អស់គួរតែត្រូវបានដាក់ដោយផ្អែកលើមូលដ្ឋានការសម្ងាត់បំផុតជាបណ្តោះអាសន្ន ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់ថា ប្រសិនបើឯកសារខ្លះ ឬឯកសារទាំងអស់ គួរត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញថាជាការសម្ងាត់នោះ[5]។ អាស្រ័យហេតុនេះ ឧបសម្ព័ន្ធនេះត្រូវបានដាក់ថាជាការសម្ងាត់បំផុត។ ដើម្បីធានាថា សហចៅក្រមស៊ើបអង្កេតបានដឹងអំពីការបង្ហាញជូននូវឯសារនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បញ្ចូលនូវនូវឯកសារទាំងនេះ នៅក្នុងបញ្ជីបែងចែកដែលស្ថិតនៅក្នុងក្របចំព័ន្ធនៃការដាក់ឯកសារនេះ៕

កាលបរិច្ឆេទ	ឈ្មោះ	ទីកន្លែង	ហត្ថលេខា
ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣	**លោក** Andrew CAYLEY សហព្រះរាជអាជ្ញាអន្តរជាតិ	ភ្នំពេញ	

[4] ឯកសារលេខ**E127/5** ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិជូនអង្គជំនុំជម្រះសាលាដំបូងអំពីកំណត់ហេតុសាក្សីនៃសំណុំរឿង០០២ នៅក្នុងសំណុំរឿង០០៣ និង០០៤ ដោយអនុវត្តតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងលេខ E127/4។

[5] ឯកសារលេខ **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង: ការបង្ហាញជូននូវកំណត់ហេតុសាក្សីសម្រាប់សាក្សីដែលអាចត្រូវផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។